ព្រះរាជក្រម

យើង

នស/រកម/១០២១/០១៤

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១៩៣
ថ្ងៃ: ព្រ.ហ. ទី ២០ ខែតុលា ឆ្នាំ២០២១
ម៉ោង: ១៧:០០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ [illegible]/២០២១ កបធ.ច ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយដែលមានសេចក្តីទាំងស្រុង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ច្បាប់នេះមានគោលបំណងបង្កើតនូវក្របខ័ណ្ឌគតិយុត្តដែលបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណទុកជាមុនបាន ប្រកបដោយភាពអំណោយផលសម្រាប់ការវិនិយោគ ដើម្បីទាក់ទាញនិងលើកកម្ពស់ការវិនិយោគដោយបុគ្គលសញ្ជាតិខ្មែរឬបរទេសប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈ៖

១- ការបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចអាចធ្វើពិពិធកម្មនិងធន់ទៅនឹងវិបត្តិក្នុងតំបន់និងសកលលោក។

២- ការធ្វើទំនើបកម្ម ការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការពង្រឹងការតភ្ជាប់ទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់និងសកលលោក តាមរយៈការជំរុញកំណើនវំហូរចូលមូលធន ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹងនិងចំណេះធ្វើ។

៣- ការបង្កើតរបបលើកទឹកចិត្តវិនិយោគមួយដែលមានតម្លាភាព ភាពអាចប៉ាន់ប្រមាណទុកជាមុនបាន គ្មានការរើសអើង មានលក្ខណៈប្រកួតប្រជែង និងគាំទ្រគោលនយោបាយសង្គម-សេដ្ឋកិច្ច។

៤- ការផ្តល់ការការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិននៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតនូវក្របខ័ណ្ឌគតិយុត្តដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានតុល្យភាពស្របទៅនឹងផលប្រយោជន៍ជាតិ។

**មាត្រា២.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

**គម្រោងវិនិយោគ** សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សរសេរជាអក្សរកាត់ គ.ល.គ. សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** សំដៅដល់ គ.ល.គ. ដែលបាន លក់ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** សំដៅដល់ **គ.ល.គ** ដែលផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក** សំដៅដល់ គ.ល.គ. ដែលមិនបម្រើឱ្យការនាំចេញ។

**គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សរសេរជាអក្សរកាត់ **គ.ព.គ.ល.គ** សំដៅដល់ការពង្រីកនៃ គ.ល.គ. ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន ឬការពង្រីកក្រោមរូបភាពផ្សេងទៀតដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ** សរសេរជាអក្សរកាត់ **គ.ធ.វ.** សំដៅដល់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយមានបញ្ជាក់ច្បាស់ថាជា គ.ធ.វ. ប៉ុន្តែពុំទទួលបានការលើកទឹកចិត្តផ្នែកសារពើពន្ធ។

**ថ្ងៃធ្វើការ** សំដៅដល់ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ធាតុចូលផលិតកម្ម** សំដៅដល់វត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច និងសម្ភារៈបន្ទាប់បន្សំរួមទាំងទំនិញ ដែលត្រូវបំប្លែងនៅក្នុងកិច្ចដំណើរការផលិតកម្ម លើកលែងតែផលិតផលគេលសិលានិងគ្រឿងបន្លាស់យានយន្ត។

**នីតិបុគ្គលសញ្ជាតិខ្មែរ** សំដៅដល់ក្រុមហ៊ុនដែលមានទីកន្លែងអាជីវកម្មនិងបានធ្វើការចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលដែលមានសញ្ជាតិខ្មែរ។

**បរិក្ខារសំណង់** សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើង ដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែកាបអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ជើងងូតទឹក ជណ្ដើរយន្ត និងទុយោ លើកលែងតែម៉ាស៊ីនត្រជាក់។ ការនាំចូលម៉ាស៊ីនត្រជាក់សម្រាប់សកម្មភាពឬគម្រោងវិនិយោគក្នុងវិស័យជាក់លាក់ណាមួយនឹងទទួលបានការលើកទឹកចិត្តដោយឡែក ដែលនឹងត្រូវកំណត់នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឬនៅក្នុងអនុក្រឹត្យ។

បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**វិញ្ញាបនបត្រចុះបញ្ជី** សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត បញ្ជាក់ពីការទទួលស្គាល់គម្រោងវិនិយោគ។

**វិនិយោគិន** សំដៅដល់បុគ្គលអនុវត្តគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**សកម្មភាពវិនិយោគ** សំដៅដល់សកម្មភាពធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានបង្កើតឡើង ឬត្រូវបានទិញយក ឬត្រូវបានលក់ ឬត្រូវបានធ្វើអនុប្បទាន ឬត្រូវបានពង្រីក ឬត្រូវបានរួមបញ្ចូលគ្នា និងត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរដោយស្ថាប័នទទួលបន្ទុកដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**សំណើសុំចុះបញ្ជីគម្រោងវិនិយោគ** សំដៅដល់សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬដាក់ជូនអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើត គ.ល.គ និងគ.ធ.វ.។ សំណើនេះអាចរាប់បញ្ចូលដំណាក់កាលមួយឬច្រើន ដោយរួមបញ្ចូលទាំងសំណើសុំពង្រីក គ.ល.គ.។

**សម្ភារៈបរិក្ខារផលិតកម្ម** សំដៅដល់គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗ សម្រាប់ប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងខ្សែច្រវាក់ផលិតកម្ម លើកលែងតែយានយន្ត។ ចំពោះការនាំចូលយានយន្តសម្រាប់សកម្មភាពឬគម្រោងវិនិយោគក្នុងវិស័យជាក់លាក់ណាមួយ នឹងទទួលបានការលើកទឹកចិត្តដោយឡែកដែលនឹងត្រូវកំណត់នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឬនៅក្នុងអនុក្រឹត្យ។

**សម្ភារៈសាងសង់** សំដៅដល់សម្ភារៈសំណង់ដែលបានបំប្លែងឬបានប្រើប្រាស់ទាំងស្រុងនៅក្នុងការសាងសង់សំណង់នានា រួមបញ្ចូលទាំង បរិក្ខារសំណង់ សម្រាប់ គ.ល.គ. ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូងឬពង្រីក។

បរិក្ខារសំណង់ សម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្ម ដូចមានចែងក្នុងមាត្រានេះត្រូវមានលក្ខខណ្ឌបច្ចេកទេសនិងបរិមាណសមស្របទៅនឹងគម្រោងវិនិយោគ។

**អ្នកដាក់ពាក្យសុំ** សំដៅដល់បុគ្គលដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា៤.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា ក.អ.ក. ជាស្ថាប័នប្រតិបត្តិពហុមុខងារជាសេនាធិការនិងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំនិងគ្រប់គ្រងកិច្ចការប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥ .-**

ក.អ.ក. មាននាយករដ្ឋមន្ត្រីជាប្រធាន ព្រមទាំងមានអនុប្រធានមួយរូបឬច្រើនរូប និងសមាជិកមួយចំនួន តាមការចាំបាច់។ អាស្រ័យដោយឆន្ទានុសិទ្ធិរបស់ខ្លួន នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិដល់ឥស្សរជនជាសមាជិកនៃរាជរដ្ឋាភិបាលឬជាថ្នាក់ដឹកនាំនៃ ក.អ.ក. ដើម្បីដឹកនាំជំនួសក្នុងកម្រិតណាមួយឬក្នុងផ្នែកណាមួយនៃការងាររបស់ ក.អ.ក. ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការបំពេញបេសកកម្មដែលមានកំណត់ក្នុងមាត្រា៤នៃច្បាប់នេះរួមបញ្ចូលនូវការគ្រប់គ្រង និងការចាត់ចែងប្រើប្រាស់ថវិកា និងធនធានមនុស្ស ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំងសមាសភាពនៃ ក.អ.ក. ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។

**មាត្រា៦ .-**

ក.អ.ក. មានរចនាសម្ព័ន្ធដូចតទៅ៖

- អគ្គលេខាធិការដ្ឋាននៃ ក.អ.ក.
- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា សរសេរជាអក្សរកាត់ថា គ.ស.អ.ក.
- គណៈកម្មាធិការវិនិយោគកម្ពុជា សរសេរជាអក្សរកាត់ថា គ.វ.ក.។

អគ្គលេខាធិការដ្ឋាននៃ ក.អ.ក. គ.ស.អ.ក. និង គ.វ.ក. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបរៀងៗខ្លួន និងអមដោយអគ្គលេខាធិការរងមួយចំនួនសម្រាប់ជាជំនួយការតាមការចាំបាច់។

ក.អ.ក. អាចបង្កើតរចនាសម្ព័ន្ធឬយន្តការបន្ថែមទៀតដោយអនុក្រឹត្យផ្អែកលើភាពចាំបាច់។

**មាត្រា៧ .-**

ក.អ.ក. មានថវិកាដោយឡែករបស់ខ្លួនដែលជាថវិកាជាតិ និងមានមន្ត្រីរាជការក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក.អ.ក. ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី៣

## យន្តការវិនិយោគរាជធានី ខេត្ត

**មាត្រា៩ .-**

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនវិនិយោគិន ការពិនិត្យ និងសម្រេចលើការវិនិយោគឯកជននិងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ ត្រូវធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ធ្វើជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត។ សិទ្ធិ អំណាច ទំហំនៃការវិនិយោគ និងការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី៤

## ការចុះបញ្ជីនិងការអនុវត្តគម្រោងវិនិយោគ

**មាត្រា១០.-**

បុគ្គលដែលមានបំណងអនុវត្ត គ.ល.គ. ឬគ.ព.គ.ល.គ. ឬគ.ធ.វ. ត្រូវដាក់សំណើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរនៅក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

សំណើសុំចុះបញ្ជីគម្រោងវិនិយោគខាងលើនេះ អាចធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា១១.-**

សំណើសុំចុះបញ្ជីគម្រោងវិនិយោគត្រូវភ្ជាប់ជាមួយនូវព័ត៌មានមួយចំនួនដែលនឹងកំណត់នៅក្នុងអនុក្រឹត្យ។

**មាត្រា១២.-**

នៅពេលទទួលបានសំណើសុំចុះបញ្ជីគម្រោងវិនិយោគ ក.អ.ក. ត្រូវពិនិត្យនិងសម្រេចលើសំណើនេះតាមយន្តការច្រកចេញ-ចូលតែមួយ។

យន្តការច្រកចេញ-ចូលតែមួយក្នុងការពិនិត្យសំណើសុំចុះបញ្ជីគម្រោងវិនិយោគ ដូចបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រានេះ គឺជាយន្តការពិនិត្យនិងសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគដោយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលប្រចាំការនៅក.អ.ក. ទៅតាមការចាត់តាំងនិងប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង ស្ថាប័ន ក្រោមការសម្របសម្រួលរបស់ក.អ.ក.។

ប្រសិនបើគម្រោងវិនិយោគដែលត្រូវបានស្នើសុំនេះមិនស្ថិតក្នុងបញ្ជីអវិជ្ជមានដែលនឹងត្រូវកំណត់ដោយឡែកក្នុងអនុក្រឹត្យ ក.អ.ក. ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ។

វិញ្ញាបនបត្រចុះបញ្ជីត្រូវមានភ្ជាប់នូវបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជី ដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និងសម្រាប់ការអនុវត្តគម្រោងវិនិយោគ។

ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាក់ព័ន្ធនិងការពិនិត្យអនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគមិនអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំ ឬអ្នកអនុវត្តគម្រោងវិនិយោគផ្តល់នូវឯកសារនានា ដែលមានស្រាប់នៅក្នុងបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលជាប់នៅលើវិញ្ញាបនបត្រចុះបញ្ជីដែលចេញដោយក.អ.ក. បានទេ។

**មាត្រា១៣.-**

គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជី អាចចាប់ផ្តើមអនុវត្តបានដោយស្វ័យប្រវត្តិ។ ការទទួលបានវិញ្ញាបនបត្រចុះបញ្ជីមិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានាឡើយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

រាល់គម្រោងវិនិយោគត្រូវជាកម្មវត្ថុនៃការតាមដាននិងត្រួតពិនិត្យតាមរយៈយន្តការច្រកចេញ-ចូលតែមួយសម្របសម្រួលដោយក.អ.ក. ដើម្បីធានានូវអនុលោមភាពតតិយុត្តនិងលក្ខខណ្ឌនានាដែលជាមូលហេតុនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី។

អ្នកអនុវត្តគម្រោងវិនិយោគត្រូវផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ទៅតាមកាលវិភាគជាក់លាក់ ដែលកំណត់ដោយក.អ.ក.។ ទម្រង់និងបែបបទលម្អិតនៃតំរូវរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក.អ.ក.។

ការផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ពុំមែនជាមូលដ្ឋាននៃការរួចផុតពីការពិនិត្យអនុលោមភាពក្នុងការអនុវត្តគម្រោងនៅនឹងកន្លែងអនុវត្តគម្រោងទេ ប្រសិនបើក.អ.ក.សន្មតថាមានភាពចាំបាច់ ឬប្រសិនបើមានការតវ៉ាណាមួយពីបុគ្គលដែលអះអាងថាបានទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោងវិនិយោគ។

**មាត្រា១៤.-**

នីតិវិធីចុះបញ្ជីគម្រោងវិនិយោគនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៥
## ការធានានិងការការពារវិនិយោគ

**មាត្រា១៥.-**

វិនិយោគិននឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើងទាក់ទងនឹងបដិទាន សំណង ឬដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងទៀត ក្នុងករណីការវិនិយោគរបស់ខ្លួនបានទទួលរងនូវការខូចខាត ដោយសារជម្លោះប្រដាប់អាវុធ ឬកលិយុគស៊ីវិល ឬការដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធ្វើបដិទានឬផ្តល់សំណងសមរម្យណាមួយនោះ។

វិនិយោគិនបរទេសមិនត្រូវជាកម្មវត្ថុនៃការរើសអើង ដោយសារមូលហេតុសញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយជាធរមាន។

**មាត្រា១៦.-**

រដ្ឋមិនត្រូវធ្វើជាតូបនីយកម្មដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់វិនិយោគិនក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា១៧.-**

រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែលនាំឱ្យប៉ះពាល់ដល់គម្រោងវិនិយោគដែលបានទទួលការអនុម័តហើយ ទោះបីដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈវិធានការប្រហាក់ប្រហែលនឹងការធ្វើអស្សាមិករណ៍ក្តី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

លើកលែងតែក្នុងករណីបម្រើប្រយោជន៍សាធារណៈ ដែលការធ្វើអស្សាមិករណ៍នេះត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ភាពមិនរើសអើង

២- សំណងដោយសមរម្យនិងយុត្តិធម៌ និង

៣- អនុលោមតាមច្បាប់និងនីតិវិធីអស្សាមិករណ៍ជាធរមាន។

**មាត្រា១៨.-**

រាជរដ្ឋាភិបាលមិនត្រូវកំណត់ថ្លៃផលិតផលឬថ្លៃសេវានានាដែលបង្កើតដោយគម្រោងវិនិយោគនោះឡើយ។

**មាត្រា១៩.-**

ដោយអនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន វិនិយោគិនមានសិទ្ធិទិញរូបិយបណ្ណបរទេសដោយសេរី និងបង្វិលទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់នោះដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន តាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង៖

១- វិភាគទានចំពោះមូលធន រាប់បញ្ចូលទាំងវិភាគទានមូលធនបឋម

២- ប្រាក់ចំណូល ចំណេញមូលធន ភាគលាភ កម្រៃសួយសារ កម្រៃអាជ្ញាបណ្ណ កម្រៃនៃការគ្រប់គ្រង និងជំនួយបច្ចេកទេស ការប្រាក់ និងប្រាក់ចំណូលដទៃទៀតដែលកើតពីការវិនិយោគ

៣- ផលដែលទទួលបានពីការលក់សរុប ឬការលក់មួយផ្នែក ឬការរំលាយក្រុមហ៊ុនដែលអនុវត្តគម្រោងវិនិយោគ

៤- ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងប្រាក់ដើម និងការប្រាក់នៃប្រាក់កម្ចី

៥- ការទូទាត់ចំពោះសំណងក្នុងករណីមានកលិយុគស៊ីវិល ក្នុងករណីមានអស្សាមិករណ៍ឬការដកហូតដោយរដ្ឋ

៦- ការទូទាត់កើតឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងសេចក្តីសម្រេចរបស់តុលាការឬសេចក្តីសម្រេចរបស់មជ្ឈត្តការ និង

៧- ចំណូលនិងប្រាក់ឈ្នួលដទៃទៀតរបស់និយោជិត។

**មាត្រា២០.-**

កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២១.-**

កម្មសិទ្ធិលើដីធ្លីរបស់វិនិយោគិនសម្រាប់បម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍ សម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលអចិន្ត្រៃយ៍ និងការជួលដែលមានអំឡុងពេលកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២២.—**

បុគ្គលដែលត្រូវបានចាត់ទុកជាវិនិយោគិន ដោយផ្អែកទៅលើច្បាប់នេះ មានសិទ្ធិដូចខាងក្រោម៖

១- សិទ្ធិជួលនិយោជិតបរទេស ដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគក្នុងចំនួនមិនលើសពីចំនួនដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីពុំអាចរកនិយោជិតខ្មែរដែលមានជំនាញដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគនោះ។ ការអនុញ្ញាតឱ្យជួលនិយោជិតបរទេសនេះ គឺត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែង និងពុំមានលក្ខណៈអចិន្ត្រៃយ៍ទេ។

២- សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់ខ្លួនឯងផ្ទាល់សម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលគម្រោងវិនិយោគរបស់ខ្លួនមានប្រតិបត្តិការ។

៣- សិទ្ធិស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់និយោជិតបរទេស និងសម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជនរបស់និយោជិតបរទេសទាំងនេះ ក្នុងអំឡុងពេលដែលកិច្ចសន្យាការងារនៅមានសុពលភាព។

៤- សិទ្ធិទទួលបានបណ្ណការងារនិងសៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់និងសម្រាប់និយោជិតបរទេសរបស់ខ្លួន។

ក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តត្រូវចេញលិខិតបញ្ជាក់អំពីឋានៈជាវិនិយោគិនជូនបុគ្គលពាក់ព័ន្ធនឹងគម្រោងវិនិយោគទៅតាមការស្នើសុំរបស់វិនិយោគិន ដើម្បីប្រើប្រាស់សម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង បណ្ណការងារនិងសៀវភៅការងារ និងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។

នីតិវិធីពិសេសសម្រាប់ការស្នើសុំបណ្ណការងារនិងសៀវភៅការងារ ដូចមានចែងក្នុងមាត្រានេះត្រូវកំណត់នៅក្នុងប្រកាសរួមរវាងក.អ.ក. និងក្រសួងទទួលបន្ទុកវិស័យការងារ។

បែបបទនិងនីតិវិធីពិសេសសម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងដូចមានចែងក្នុងមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា២៣.—**

វិនិយោគិនមានសិទ្ធិទទួលបាននូវសេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៦
## ការលើកទឹកចិត្តវិនិយោគ

**មាត្រា២៤.-**

វិស័យនិងសកម្មភាពវិនិយោគដូចខាងក្រោម ត្រូវទទួលការលើកទឹកចិត្ត៖

១- ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ប្រកបដោយនវានុវត្តន៍ និងការស្រាវជ្រាវនិងអភិវឌ្ឍ

២- ឧស្សាហកម្មឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់

៣- ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក

៤- ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក និងឧស្សាហកម្មភ្ជាប់បណ្តាញផ្គត់ផ្គង់

៥- ឧស្សាហកម្មគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក

៦- ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និងតម្លើង

៧- ឧស្សាហកម្មមេកានិកនិងគ្រឿងម៉ាស៊ីន

៨- កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុកឬការនាំចេញ

៩- សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម សួនឧស្សាហកម្ម និងសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០- ឧស្សាហកម្មទេសចរណ៍និងសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍

១១- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

១២- ឧស្សាហកម្មឌីជីថល

១៣- ការវិនិយោគក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជំរុញផលិតភាព

១៤- ការវិនិយោគក្នុងវិស័យសុខាភិបាល

១៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១៦- ការវិនិយោគក្នុងវិស័យឡូជីស្ទីក

១៧- ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ និងសេដ្ឋកិច្ចចក្រា

១៨- ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យាដែលរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

១៩- វិស័យនិងសកម្មភាពវិនិយោគផ្សេងទៀតដែលមិនមានចែងក្នុងច្បាប់នេះ ក្នុងករណីដែលរាជរដ្ឋាភិបាលយល់ឃើញថាមានសក្តានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

**មាត្រា២៥.-**

វិស័យនិងសកម្មភាពវិនិយោគដែលមានចែងក្នុងមាត្រា២៤នៃច្បាប់នេះដែលមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន ត្រូវទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬពន្ធគយទាំងស្រុងឬមួយផ្នែក ក្រោយពីបានទទួលវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ.ល.គ។

វិស័យនិងសកម្មភាពវិនិយោគដែលមានចែងក្នុងមាត្រា២៤នៃច្បាប់នេះដែលពុំទទួលបានការលើកទឹកចិត្តទាំងផ្នែកពន្ធដារនិងពន្ធគយត្រូវបានកំណត់ក្នុងបញ្ជីអវិជ្ជមានដែលនឹងចែងដោយអនុក្រឹត្យ។

**មាត្រា២៦ .–**

សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ល.គ មានសិទ្ធិជ្រើសរើសការលើកទឹកចិត្តជាមូលដ្ឋានជាពីរជម្រើសដូចខាងក្រោម៖

១. ជម្រើសទី១

- ការលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់រយៈពេលចាប់ពី៣(បី)ឆ្នាំ រហូតដល់៩(ប្រាំបួន)ឆ្នាំ ទៅតាមវិស័យនិងសកម្មភាពវិនិយោគ គិតចាប់ពីពេលដែលទទួលបានប្រាក់ចំណូលលើកដំបូង។ វិស័យនិងសកម្មភាពវិនិយោគ ព្រមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល នឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល គ.ល.គ. មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងទឹកប្រាក់ពន្ធត្រូវបង់សរុប ដូចខាងក្រោម៖
  - ២៥(ម្ភៃប្រាំ)ភាគរយ សម្រាប់២(ពីរ)ឆ្នាំដំបូង
  - ៥០(ហាសិប)ភាគរយ សម្រាប់២(ពីរ)ឆ្នាំបន្ទាប់ និង
  - ៧៥(ចិតសិបប្រាំ)ភាគរយ សម្រាប់២(ពីរ)ឆ្នាំចុងក្រោយ។
- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ក្នុងអំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល។
- ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។
- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ឬ

២. ជម្រើសទី២

- មានសិទ្ធិកាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេស ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។
- មានសិទ្ធិកាត់កងរហូតដល់២០០(ពីររយ)ភាគរយ លើចំណាយជាក់លាក់ផ្សេងទៀត សម្រាប់រយៈពេលរហូតដល់៩(ប្រាំបួន)ឆ្នាំ។ វិស័យ និងសកម្មភាពវិនិយោគ និងចំណាយជាក់លាក់ព្រមទាំងរយៈពេលកាត់កងចំណាយ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។
- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ក្នុងរយៈពេលជាក់លាក់ណាមួយទៅតាមវិស័យ និងសកម្មភាពវិនិយោគ ដែលត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។
- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

ក្រៅពីការលើកទឹកចិត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ៖

ក. គ.ឈ.គ បម្រើឱ្យការនាំចេញ និង គ.ឈ.គ ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ឈ.គ បម្រើឱ្យការនាំចេញ មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។

ខ. គ.ឈ.គ. បម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម។ ការលើកទឹកចិត្តចំពោះធាតុចូលផលិតកម្ម ត្រូវកំណត់ក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។

គ.ឈ.គ. ដែលមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងការការពារដូចគ្នានឹង គ.ឈ.គ. ផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា២៧.-**

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋាន ដែលមានចែងក្នុងមាត្រា២៦នៃច្បាប់នេះ សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ឈ.គ. ទទួលបានការលើកទឹកចិត្តបន្ថែម ដូចខាងក្រោម៖

១- ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញធាតុចូលផលិតកម្មដែលផលិតក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្ត គ.ឈ.គ.។

២- ទទួលបានការកាត់កងចំណាយក្នុងអត្រា ១៥០(មួយរយហាសិប)ភាគរយ ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

ក. ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍

ខ. ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ

គ. ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀតសម្រាប់កម្មករនិយោជិត

ឃ. ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើឱ្យខ្សែច្រវាក់ផលិតកម្ម

ង. ការផ្ដល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្ដល់មធ្យោបាយដឹកជញ្ជូនប្រកបដោយជាសុកភាពដល់កម្មករនិយោជិត ក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅរោងចក្រ កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល ចំពោះការពង្រីកនៃ គ.ល.គ. ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ .-**

បន្ថែមពីលើការលើកទឹកចិត្តដូចមានកំណត់ក្នុងមាត្រា២៦និងមាត្រា២៧នៃច្បាប់នេះ វិស័យនិងសកម្មភាពវិនិយោគជាក់លាក់ណាមួយដែលមានសក្តានុពលខ្ពស់ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ អាចទទួលការលើកទឹកចិត្តពិសេសដោយឡែកផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។

## ជំពូកទី៧

## ការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ

**មាត្រា២៩ .-**

សិទ្ធិ បុព្វសិទ្ធិ ឬសិទ្ធិដទៃទៀត ដែល គ.ល.គ. បានទទួលមិនអាចផ្ទេរទៅតតិយជនណាមួយបានទេ លើកលែងតែការផ្ទេរតាមរយៈការទិញ ការលក់ និងការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ។

**មាត្រា៣០ .-**

គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នាដោយមិនបាត់បង់ការលើកទឹកចិត្ត ការធានាលើការវិនិយោគ និងកាតព្វកិច្ចទាំងឡាយដែលនៅមានបន្ត ប្រសិនបើការទិញ ការលក់ ឬការរួមបញ្ចូលគ្នានោះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយត្រូវបានធ្វើឡើងតាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដែលនីតិវិធីលម្អិតត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## ការលុបគម្រោងវិនិយោគ

**មាត្រា៣១ .-**

គម្រោងវិនិយោគអាចត្រូវបានលុបក្នុងករណីណាមួយដូចខាងក្រោម៖

១- អលទ្ធភាពក្នុងការអនុវត្ត គ.ល.គ. បន្តទៀត។

២- នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ។

៣- ការខកខានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣២ .-**

ក្នុងករណីការលុបដោយលក្ខខណ្ឌដូចមានចែងក្នុងចំណុច១នៃមាត្រា៣១នៃច្បាប់នេះ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ លិខិតស្នើសុំខាងលើនេះត្រូវចុះហត្ថលេខាដោយវិនិយោគិន ឬអ្នកតំណាងដែលមានសិទ្ធិ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃអលទ្ធភាពនេះ និងត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រផ្សេងៗ។

ក្នុងករណីការលុបដោយការរំលាយដូចមានចែងក្នុងចំណុច២នៃមាត្រា៣១នៃច្បាប់នេះ ប្រសិនបើការរំលាយនេះធ្វើឡើងដោយការជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត នោះវិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

ក្នុងករណីការលុបដោយការរំលាយដូចមានចែងក្នុងចំណុច២នៃមាត្រា៣១នៃច្បាប់នេះ ប្រសិនបើការរំលាយនេះធ្វើឡើងដោយសេចក្តីសម្រេចរបស់តុលាការ វិនិយោគិនអាចដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវ សេចក្តីសម្រេចស្ថាពររបស់តុលាការនិងឯកសារពាក់ព័ន្ធអំពីការរំលាយនីតិបុគ្គលដែលអនុវត្ត គ.ល.គ. និងសេចក្តីបញ្ជាក់ពីទំនាក់ទំនងផលប្រយោជន៍ជាមួយ គ.ល.គ. ដែលត្រូវលុបនេះផងដែរ។

គ.ល.គ. អាចត្រូវបានលុបដោយឆន្ទានុសិទ្ធិរបស់ក.អ.ក.ឬរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយអនុលោមតាមលក្ខខណ្ឌដូចមានកំណត់ក្នុងចំណុច៣នៃមាត្រា៣១នៃច្បាប់នេះ។

នីតិវិធីលម្អិតស្តីពីការស្នើសុំលុបនិងការលុបដោយឆន្ទានុសិទ្ធិ ដូចមានកំណត់ពីចំណុច១ ដល់ចំណុច៤នៃមាត្រា៣១នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៣ .-**

ទោះបីជាគម្រោងវិនិយោគត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធនិងកាតព្វកិច្ចដទៃផ្សេងៗទៀតឡើយ។

**មាត្រា៣៤ .-**

វិនិយោគិនអាចធ្វើការតវ៉ាចំពោះការលុបគម្រោងវិនិយោគបាន តាមរយៈការដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ស្របតាមនីតិវិធីជាធរមាន។

ក្នុងករណីមានការតវ៉ា ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវធ្វើសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ វិនិយោគិនដែលបានតវ៉ា អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៥ .-**

ក្នុងករណីដែលគម្រោងវិនិយោគត្រូវបានលុប វិនិយោគិនអាចផ្ទេរទ្រព្យសម្បត្តិដែលសេសសល់ ទៅក្រៅប្រទេសឬប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលគម្រោងវិនិយោគបានប្រើសម្ភារៈសាងសង់

បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ក្នុងអំឡុងពេលតិចជាង៥(ប្រាំ)ឆ្នាំ វិនិយោគិនមានកាតព្វកិច្ចបង់ពន្ធលើសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មផ្សេងៗទាំងនោះ ដែលត្រូវកំណត់ដោយអនុក្រឹត្យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## វិវាទនិងការដោះស្រាយវិវាទ

**មាត្រា៣៦ .–**

វិវាទរវាងវិនិយោគិននិងវិនិយោគិនពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគ អាចត្រូវបានដោះស្រាយតាមយន្តការសម្របសម្រួលដោយក.អ.ក.ឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត តាមនីតិវិធីជាធរមានតាមការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភាគីវិវាទណាមួយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានសំណើសុំជាលាយលក្ខណ៍អក្សរដែលស្នើសុំសម្របសម្រួល ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចាត់ចែងរៀបចំការសម្របសម្រួលជាមួយវិនិយោគិននិងអង្គពាក់ព័ន្ធដទៃទៀតទៅតាមការចាំបាច់ សំដៅទទួលបានដំណោះស្រាយសមរម្យមួយ។

ប្រសិនបើការដោះស្រាយតាមយន្តការសម្របសម្រួលខាងលើពុំទទួលបានជោគជ័យ វិវាទអាចត្រូវបានដោះស្រាយតាមរយៈ៖

១- មជ្ឈត្តការជាតិឬមជ្ឈត្តការអន្តរជាតិដែលយល់ព្រមដោយគូវិវាទ

២- តុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១០
## ការអនុវត្ត

**មាត្រា៣៧ .–**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជរដ្ឋាភិបាលត្រូវចេញអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៣៨ .–**

អនុក្រឹត្យដូចខាងក្រោមត្រូវបន្តមានសុពលភាពរហូតដល់មានអនុក្រឹត្យឬលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

១. អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២. អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត។

៣. អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលផ្នែកទី១ ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៤. អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥. អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៦. អនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

៧. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៣៩.-**

ក.អ.ក ត្រូវបន្តអនុវត្តភារកិច្ចរបស់ខ្លួន រហូតដល់មានព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមកជំនួស។

**មាត្រា៤០.-**

ការវិនិយោគទាំងឡាយដែលបានទទួលការលើកទឹកចិត្ត និងដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកជា គ.ល.ត. ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

ការវិនិយោគទាំងឡាយដែលពុំបានទទួលការលើកទឹកចិត្តឬទទួលបានត្រឹមតែលើការធានាការវិនិយោគ និងដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកជា **គ.ធ.វ.** ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

ត.ល.ត. ដែលមានសិទ្ធិទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូល មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ ហើយដែលសិទ្ធិទទួលបាននេះត្រូវបានអនុម័តជាលាយលក្ខណ៍អក្សរដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវបន្តទទួលបាននូវសិទ្ធិនិងការលើកលែងពន្ធលើប្រាក់ចំណូលត្រឹមទំហំដែលនៅសេសសល់តែប៉ុណ្ណោះ។

## ជំពូកទី១២

## អវសានប្បញ្ញត្តិ

**មាត្រា៤១ .-**

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៤២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសុក្រ ៩កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០២១

[illegible]

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**